## ២.៤ ការចូលរៀន គុណភាព និង ប្រសិទ្ធភាពអប់រំមធ្យមសិក្សាបឋមភូមិ

### វត្ថុបំណង និង យុត្តិកម្ម

វត្ថុបំណងនៃកម្មវិធីនេះ គឺកាត់បន្ថយឧបសគ្គនៃការចូលរៀន និងកែលំអគុណភាព និងប្រសិទ្ធភាព ដើម្បីបង្កើនអត្រាគង់វង្សពីថ្នាក់ទី ៧ ដល់ទី ៩ និងអត្រាឆ្លងភូមិសិក្សាពីថ្នាក់ទី ៩-១០ ។

### អាំងឌីកាទ័រ និងចំណុចដៅ

- អត្រាពិតនៃការសិក្សានៅថ្នាក់ទី ៧-៩ កើនពី ២៦.១% (ឆ្នាំសិក្សា២០០៤-០៥) ដល់ ៣៩% នៅឆ្នាំ ២០០៨ ។
- កាត់បន្ថយគំលាតយេនឌ័រអត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ ពី ២.៥% (ឆ្នាំសិក្សា ២០០៤ -០៥) ដល់ 0% នៅឆ្នាំ ២០១០ ។
- អត្រាឆ្លងភូមិសិក្សានៅថ្នាក់ទី ៩-១០ កើនពី ៥៦.១% (ឆ្នាំសិក្សា២០០៤-០៥) ដល់ ៧៨% នៅឆ្នាំ ២០១០ ។
- ដាក់អោយអនុវត្តស្តង់ដាលទ្ធផលនៃការសិក្សាអប្បបរមា នៅគ្រប់សាលាមធ្យមសិក្សាបឋមភូមិ ។

### យុទ្ធសាស្ត្រ និង វិសាលភាព

យុទ្ធសាស្ត្ររបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការធានាសមធម៌នៃការចូលរៀន គឺកាត់បន្ថយចំណាយដែលជាឧបសគ្គសម្រាប់គ្រួសារសិស្សក្រីក្រ តាមរយៈការបង្កើនមូលនិធិរបស់រាជរដ្ឋាភិបាលសម្រាប់ថវិកាដំណើរការសាលារៀន ។ កម្មវិធីនេះត្រូវបានបំពេញបន្ថែមដោយកម្មវិធីអាហារូបករណ៍/ការលើកទឹកចិត្ត (កសអ១២) ដើម្បីផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រថ្នាក់ទី ៧-៩ ដែលជាចំណែកមួយក្នុងការកាត់បន្ថយបន្ទុកចំណាយរបស់គ្រួសារក្រីក្រ ។ កម្មវិធីក៏មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការពង្រីកសម្ភាររូបវ័ន្តមធ្យមសិក្សាបឋមភូមិ ការពង្រាយគ្រូបង្រៀន និងកំណែទម្រង់ការបណ្តុះបណ្តាល ដើម្បីអោយប្រាកដថា គ្រូបង្រៀនដែលមានគុណភាព ត្រូវបានផ្តល់គ្រប់គ្រាន់សម្រាប់សាលារៀនបើកថ្មី ។

ម្យ៉ាងទៀត ដើម្បីសម្រេចវត្ថុបំណងនៃការកាត់បន្ថយបន្ទុកចំណាយរបស់មាតាបិតាសិស្ស ក្រសួងនឹងអនុវត្តវិធានការក្នុងការកែលំអគុណភាពអប់រំ ដែលរួមមាន ១) ការពង្រឹងប្រព័ន្ធប្រលងថ្នាក់ទី៩, ២) ការអនុវត្តស្តង់ដាអប្បបរមាក្នុងការវាយតម្លៃសិស្ស ដើម្បីកែលំអគុណភាពបង្រៀន និងរៀន ៣) បង្កើនតម្លាភាព និងគណនេយ្យភាពរបស់សាលារៀន តាមរយៈការដាក់អោយអនុវត្តប្រព័ន្ធពិនិត្យតាមដានការបំពេញការងារសាលារៀន និងប័ណ្ណរាយការណ៍ ។

### កម្មវិធី និង សកម្មភាពចម្បងៗ

- បង្កើនថវិកាដំណើរការសាលារៀននៅទូទាំងប្រទេស ដោយផ្អែកលើការកែប្រែកញ្ចប់ថវិកាប្រចាំឆ្នាំ និងរូបមន្តបែងចែកថវិកាសម្រាប់សិស្សម្នាក់ដែលបានឯកភាព ។

- អនុវត្តប្រព័ន្ធគណនេយ្យភាព និងកសាងផែនការហិរញ្ញវត្ថុថ្មី សម្រាប់ថវិកាដំណើរការសាលារៀន ដោយមានការចូលរួមលើការគ្រប់គ្រងពីមាតាបិតាសិស្ស និងតំណាងសហគមន៍ ។
- ពង្រីកសាលាបឋមសិក្សាបច្ចុប្បន្ន អោយទៅជាសាលារៀនអប់រំមូលដ្ឋាន ដែលមានពីថ្នាក់ទី ១-៩ (អនុវត្តក្រោមកម្មវិធីចំណាយជាមូលធន) ។
- ផ្តល់អាហារូបករណ៍សម្រាប់សិស្សក្រីក្រនៅទូទាំងប្រទេស ពិសេសសិស្សស្រី ដើម្បីកាត់បន្ថយបន្ទុកចំណាយ ដែលជាឧបសគ្គដល់ការចូលរៀននៅមធ្យមសិក្សាបឋមភូមិ ។
- ផ្តល់បំណិនជីវិតមិត្តអប់រំមិត្ត ក្រោមកម្មវិធីមេរោគហ៊ីវ/ជម្ងឺអេដស៍របស់ក្រសួងអប់រំ យុវជន និង កីឡា ដោយសហការជាមួយអង្គការក្រៅរដ្ឋាភិបាលមួយចំនួន[១] ។

## ការគ្រប់គ្រង និង ការពិនិត្យតាមដានកម្មវិធី

នាយកដ្ឋានមធ្យមសិក្សា គ្រប់គ្រងការពិនិត្យតាមដានកម្មវិធីនេះ ។ ការពិនិត្យតាមដានការរីកចម្រើនជាទៀងទាត់ ជាទំនួលខុសត្រូវរបស់ក្រុមអធិការកិច្ចមធ្យមសិក្សា និងអ្នកត្រួតពិនិត្យរបស់ការិយាល័យអប់រំ យុវជន និងកីឡាស្រុក-ខ័ណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ស្របទៅតាមផែនការការងារ និងផែនការអភិវឌ្ឍសាលារៀនដែលបានឯកភាព ។

BMCs ទាំង ១៨៥ ស្រុក-ខ័ណ្ឌ គ្រប់គ្រងថវិការបស់កម្មវិធីនេះ និង បើកផ្តល់សាច់ប្រាក់ទៅអោយសាលារៀន ។ ការពិនិត្យតាមដានវឌ្ឍនភាពនៃការចំណាយសាច់ប្រាក់ ជាទំនួលខុសត្រូវរបស់សមាជិក BMCs ដែលបានតែងតាំង ។ BMCs ស្រុក-ខ័ណ្ឌនីមួយៗ ត្រូវធ្វើរបាយការណ៍ប្រចាំខែជូនដល់ BMCs ខេត្ត-ក្រុង ស្តីពីសកម្មភាពបច្ចេកទេស និងស្ថានភាពហិរញ្ញវត្ថុរបស់កម្មវិធី ។ ការបែងចែកថវិកាសម្រាប់កម្មវិធីនេះ ត្រូវបានផ្តល់ដល់កំរងសាលារៀន សម្រាប់ជួយឧបត្ថម្ភក្នុងការពិនិត្យតាមដាន និងការគាំទ្រសាលារៀន ។

BMCs មន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ទទួលខុសត្រូវក្នុងការពិនិត្យតាមដានលទ្ធផល និងការរីកចម្រើនទូទៅនៃសកម្មភាពផ្នែកបច្ចេកទេស និងការផ្តល់ហិរញ្ញប្បទានរបស់កម្មវិធី កែលំអកំហុសឆ្គងពេលចាំបាច់ និងធានាការបញ្ជូនរបាយការណ៍ប្រចាំខែទាន់ពេលវេលារបស់ BMCs ការិយាល័យអប់រំ យុវជន និងកីឡាស្រុក-ខ័ណ្ឌ ។ BMCs ខេត្ត-ក្រុង ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាសជូន BMCs នាយកដ្ឋានមធ្យមសិក្សា ទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ។

---

[១] *មានការគាំទ្រ តាមរយៈគណៈកម្មការអន្តរនាយកដ្ឋានស្តីពីមេរោគហ៊ីវ/ជម្ងឺអេដស៍ (ICHA)*

## ផែនការហិរញ្ញវត្ថុ

*តារាងទី៤ : ផែនការហិរញ្ញវត្ថុសម្រាប់ការចូលរៀន គុណភាព និងប្រសិទ្ធភាពអប់រំមធ្យមសិក្សាបឋមភូមិ*

| សកម្មភាព | ចំណាយគិតជាលានរៀល | | | | |
|---|---|---|---|---|---|
| | 2006 | 2007 | 2008 | 2009 | 2010 |
| 1. ថវិកាដំណើរការសាលារៀន | 13,500 | 17,000 | 22,100 | 26,400 | 30,700 |
| 2. ពង្រឹងសមត្ថភាពគ្រប់គ្រង និងបង្រៀន | 2,000 | 2,000 | 2,000 | 2,000 | 2,000 |
| 3. ការពង្រឹងការពិនិត្យតាមដាន | 800 | 870 | 965 | 1,048 | 1,130 |
| **ធនធានសរុប** | **16,350** | **19,870** | **25,065** | **29,448** | **33,830** |

## តម្រូវការកសាងសមត្ថភាព

- ពង្រឹងសមត្ថភាពមន្ត្រីអប់រំនៅគ្រប់កំរិតថ្នាក់សម្រាប់ធ្វើរបាយការណ៍ ពិនិត្យតាមដានហិរញ្ញវត្ថុ និងអធិការកិច្ចសាលារៀន ផ្សារភ្ជាប់ទៅនឹងការដាក់អោយអនុវត្តប្រព័ន្ធពិនិត្យតាមដានការបំពេញការងាររបស់សាលារៀន ដើម្បីបង្កើនតម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រងសាលារៀន ។
- គាំទ្រដល់ការពង្រឹងការបំពេញការងាររបស់នាយកសាលារៀន និងគ្រូបង្រៀន ដោយផ្តោតជាពិសេសលើការពង្រឹងការគ្រប់គ្រងសាលារៀន វិធីសាស្រ្តបង្រៀន និងរៀន និងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ។
- គាំទ្រដល់ការអនុវត្តបំណិនជីវិត គោលនយោបាយស្តីពីមេរោគហ៊ីវ/ជម្ងឺអេដស៍ សុខភាពបន្តពូជ (Reproductive Health Policies) និងកម្មវិធីនានា តាមរយៈការផ្តល់សៀវភៅសិក្សាស្តីពីបំណិនជីវិត ធនធាន និងការបណ្តុះបណ្តាលគ្រូបំណិនជីវិត ។
- រៀបចំយុទ្ធសាស្រ្ត និងកម្មវិធីសម្រាប់ពង្រឹងបន្ថែមការចូលរួមរបស់សហគមន៍ក្នុងការងារអប់រំ និងការគ្រប់គ្រងសាលារៀន ដើម្បីជួយដល់ការអភិវឌ្ឍសាលារៀន ការកាត់បន្ថយអត្រាបោះបង់ ។
- គាំទ្រដល់ការពង្រឹងការងារគ្រប់គ្រង និងការប្រលងឆមាសនៅគ្រប់កំរិតថ្នាក់ និងការប្រលងថ្នាក់ជាតិថ្នាក់ទី ៩ និងទី ១២ ពិសេសតាមរយៈការដាក់ចេញសេចក្តីណែនាំស្តីពីការប្រលង លិខិតបទដ្ឋាន និងការរៀបចំយន្តការប្រលងអោយបានល្អ ដើម្បីធានាអោយមានគុណភាព និងប្រសិទ្ធភាព ។
- គាំទ្រដល់ការរៀបចំសេចក្តីណែនាំ និងអាណត្តិអោយបានច្បាស់លាស់ ស្តីពីតួនាទី ការទទួលខុសត្រូវ និងនីតិវិធីការងារ ដែលទាក់ទងទៅនឹងការគ្រប់គ្រងសកម្មភាពមធ្យមសិក្សា នៅថ្នាក់រដ្ឋបាលកណ្តាល ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និងសាលារៀន ។
- គាំទ្រដល់ការពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងរបាយការណ៍ ព្រមទាំងនីតិវិធីការងារនៅថ្នាក់កណ្តាល ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និងសាលារៀន ស្របគ្នាទៅនឹងការពង្រឹងការប្រមូលទិន្នន័យ និងការវិភាគនៅគ្រប់លំដាប់ថ្នាក់ ។